**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ....................មស.នបុ

## សំណើសុំច្បាប់និងការអនុញ្ញាតច្បាប់ឈប់សម្រាកគ្រប់ប្រភេទ
## របស់មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

**យោង ៖** អនុក្រឹត្យលេខ២១៧ អនក្រ.បក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ស្តីពីរបបស្តីពីការសុំច្បាប់និងការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទ របស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

១- គោត្តនាមនិងនាម.................................... ភេទ ....... អត្តលេខ ......................... មុខតំណែង ..................................
អង្គភាព.................................................................................................. ទូរស័ព្ទ...................................................

២- ប្រភេទនៃច្បាប់ឈប់សម្រាកដែលត្រូវស្នើសុំ ៖

☐ ឈប់ប្រចាំឆ្នាំ ☐ ឈប់រយៈពេលខ្លី ☐ ឈប់សម្រាកលំហែមាតុភាព
☐ ឈប់សម្រាកព្យាបាលជម្ងឺ ☐ ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន

៣- ចំនួនថ្ងៃស្នើសុំឈប់ កាលបរិច្ឆេទនៃការចាប់ផ្តើមឈប់ និងកាលបរិច្ឆេទនៃការចូលបម្រើការងារវិញ

- ចំនួនថ្ងៃស្នើសុំឈប់ ៖ ........................................................................................
- ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើមឈប់ ៖ ........................................................................................
- ថ្ងៃ ខែ ឆ្នាំ ចូលបម្រើការងារវិញ ៖ ........................................................................................

៤- គោលបំណង ..............................................................................................................................
..............................................................................................................................................

| ☐ អនុញ្ញាត<br>☐ មិនអនុញ្ញាត | ☐ អនុញ្ញាត<br>☐ មិនអនុញ្ញាត | រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..........ឆ្នាំ២...... |
|---|---|---|
| ហត្ថលេខាប្រធានអង្គភាពសាមី | ហត្ថលេខាប្រធានការិយាល័យ | ហត្ថលេខារបស់មន្ត្រីស្នើសុំ |
| ..................................................... | ..................................................... | ..................................................... |
| ..................................................... | ..................................................... | ..................................................... |

៥- នាយកដ្ឋានគ្រប់គ្រងបុគ្គលិកដើម្បីជ្រាបជាព័ត៌មាន និងការផ្ទៀងផ្ទាត់

| | ឈប់ប្រចាំឆ្នាំ | ឈប់រយៈពេលខ្លី | ឈប់សម្រាកលំហែមាតុភាព | ឈប់សម្រាកព្យាបាលជម្ងឺ | ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន |
|---|---|---|---|---|---|
| ចំនួនថ្ងៃឈប់សម្រាក | | | | | |
| ចំនួនថ្ងៃនៅសល់ | | | | | |

- ហត្ថលេខានិងកាលបរិច្ឆេទរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងបុគ្គលិក
..............................................................................................................................
..............................................................................................................................
..............................................................................................................................

៦- ការអនុញ្ញាតរបស់ប្រធានស្ថាប័ន/អង្គភាព

☐ អនុញ្ញាត ☐ មិនអនុញ្ញាត

យោបល់ ៖ ..............................................................................................................................
..............................................................................................................................

- ហត្ថលេខានិងកាលបរិច្ឆេទរបស់ប្រធានស្ថាប័ន/អង្គភាព
..............................................................................................................................
..............................................................................................................................
..............................................................................................................................

<u>សេចក្តីបញ្ជាក់</u>៖ ពេលចូលបម្រើការងារវិញមន្ត្រីសាមីត្រូវប្រគល់សំណើសុំច្បាប់និងការអនុញ្ញាតច្បាប់ឈប់សម្រាកគ្រប់ប្រភេទរបស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជានេះឲ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងបុគ្គលិក។

ជំពូកទី២ ៖ ច្បាប់ឈប់ប្រចាំឆ្នាំ

មាត្រា៥ មន្ត្រីរាជការស៊ីវិលដែលតាំងស៊ប់ក្នុងក្របខ័ណ្ឌមានសិទ្ធិទទួលបានច្បាប់ឈប់សម្រាក ចំនួន ១៥ថ្ងៃ នៃថ្ងៃធ្វើការក្នុង ០១ឆ្នាំ ហើយអាចឈប់បាន ចំនួន ៣០ថ្ងៃ បើមន្ត្រីនោះបម្រើការងារបាន ០២ ឆ្នាំជាប់គ្នា។

ជំពូកទី៣ ៖ ច្បាប់ឈប់រយៈពេលខ្លី

មាត្រា៨ មានសិទ្ធិស្នើសុំឈប់ ចំនួន ១៥ ថ្ងៃ នៃថ្ងៃធ្វើការក្នុង ០១ឆ្នាំ។

មានសិទ្ធិស្នើសុំឈប់ លើសចំនួន ១៥ ថ្ងៃ ប៉ុន្តែត្រូវកាត់ចំនួនថ្ងៃដែលឈប់លើសនោះចេញពីចំនួនថ្ងៃនៃច្បាប់ឈប់សម្រាកប្រចាំឆ្នាំ។

មាត្រា៩ ច្បាប់ឈប់រយៈពេលខ្លី ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ដូចខាងក្រោម ៖

១. ពី១(មួយ)ថ្ងៃដល់៥(ប្រាំ)ថ្ងៃ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីប្រធានអង្គភាពដែលគ្រប់គ្រងផ្ទាល់ លើកលែងតែ ៖

- អភិបាលរាជធានី ខេត្ត ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីអភិបាលរាជធានី ខេត្ត
- ប្រធានមន្ទីរជំនាញរាជធានី ខេត្ត ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីអភិបាលរាជធានី ខេត្ត ដោយជូនដំណឹងទៅក្រសួង ស្ថាប័នរបស់ខ្លួន។

២. ពី៦(ប្រាំមួយ)ថ្ងៃឡើងទៅ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ដូចតទៅ ៖

ក. ចំពោះមន្ត្រីរាជការស៊ីវិលថ្នាក់រាជធានី ខេត្ត ៖

- អភិបាលរាជធានី ខេត្ត ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- អភិបាលរងរាជធានី ខេត្ត មន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត និងអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីអភិបាលរាជធានី ខេត្ត
- អភិបាលរងក្រុង ស្រុក ខណ្ឌ មន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធសាលាក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីអភិបាលក្រុង ស្រុក ខណ្ឌ
- ប្រធានមន្ទីរជំនាញរាជធានី ខេត្ត ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីក្រសួង ស្ថាប័ន តាមរយៈអភិបាលរាជធានី ខេត្ត
- អនុប្រធានមន្ទីរជំនាញ រាជធានី ខេត្ត មន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធមន្ទីរជំនាញរាជធានី ខេត្ត និងប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីប្រធានមន្ទីរជំនាញរាជធានី ខេត្ត
- អនុប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ មន្ត្រីបម្រើការងារក្នុងការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ។

ខ. ចំពោះមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីថ្នាក់ដឹកនាំក្រសួង ស្ថាប័ន។

ជំពូកទី៤ ៖ ច្បាប់ឈប់សម្រាកលំហែមាតុភាព

មាត្រា១០ មន្ត្រីរាជការជាស្ត្រី ត្រូវអនុញ្ញាតច្បាប់ឈប់សម្រាករយៈពេល ០៣ខែ ដោយភ្ជាប់លិខិតបញ្ជាក់ពីគ្រូពេទ្យមានសមត្ថកិច្ច។

ជំពូកទី៥ ៖ ច្បាប់ឈប់សម្រាកព្យាបាលជំងឺ

មាត្រា១២ ត្រូវបានអនុញ្ញាតឲ្យឈប់ពី ០១ខែ ទៅ ០៣ខែ ក្នុងមួយលើក បើពិនិត្យឃើញថាមានជំងឺមិនអាចមកបម្រើការងារបាន អាចសុំឈប់បន្តទៀតបានមិនឲ្យលើស ពី ១២ខែ ក្នុងអំឡុងបម្រើការងារជាមន្ត្រីរាជការស៊ីវិល ហើយការសុំបន្តនេះត្រូវមានលិខិតបញ្ជាក់ពីគ្រូពេទ្យមានសមត្ថកិច្ច។

- ច្បាប់ឈប់សម្រាកព្យាបាលជំងឺបន្ទាប់ទៀតលើសពី០៣ខែ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីថ្នាក់ដឹកនាំក្រសួង ស្ថាប័ន។

ជំពូកទី៦ ៖ ច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន

មាត្រា១៧ ច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន ត្រូវបានអនុញ្ញាតឲ្យមន្ត្រីរាជការស៊ីវិល ដើម្បីការពារផលប្រយោជន៍ផ្ទាល់ខ្លួន និងគ្រួសារមានរយៈពេលក្នុងមួយលើកយ៉ាងតិច១(មួយ)ខែ រយៈពេលសរុបមិនឲ្យលើសពី៣(បី)ខែឡើយ ក្នុងអំឡុងបម្រើការងារជាមន្ត្រីរាជការស៊ីវិល។

ក្នុងករណីឈប់លើសការកំណត់ខាងលើ មន្ត្រីរាជការស៊ីវិលនោះ ត្រូវដាក់ឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ។ បើពិនិត្យឃើញថាមន្ត្រីរាជការស៊ីវិលដែលទទួលបានការអនុញ្ញាតច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន ពុំអនុវត្តត្រឹមត្រូវដូចការអះអាងទេនោះ ប្រធានស្ថាប័ន ត្រូវកោះអញ្ជើញឲ្យមន្ត្រីរាជការស៊ីវិលចូលបម្រើការងារវិញជាបន្ទាន់។

- ច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីថ្នាក់ដឹកនាំក្រសួង ស្ថាប័ន។

មាត្រា១៨ មន្ត្រីរាជការស៊ីវិល ដែលទទួលបានការអនុញ្ញាតច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន ត្រូវទទួលបានបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ចំនួនពាក់កណ្ដាល។

សម្គាល់ ៖ ជំពូកទី២ មាត្រា៦ ចំណុច ក និង ខ

ជំពូកទី៤ មាត្រា១១ ចំណុច ក និង ខ

ជំពូកទី៥ មាត្រា១៣ ចំណុច ក និង ខ

ក. ចំពោះមន្ត្រីរាជការថ្នាក់រាជធានី ខេត្ត ៖

- អភិបាលរាជធានី ខេត្ត ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- អភិបាលរងរាជធានី ខេត្ត មន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត និងអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីអភិបាលរាជធានី ខេត្ត
- អភិបាលរងក្រុង ស្រុក ខណ្ឌ មន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធសាលាក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីអភិបាលក្រុង ស្រុក ខណ្ឌ
- ប្រធានមន្ទីរជំនាញរាជធានី ខេត្ត ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីក្រសួង ស្ថាប័ន តាមរយៈអភិបាលរាជធានី ខេត្ត
- អនុប្រធានមន្ទីរជំនាញរាជធានី ខេត្ត មន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធមន្ទីរជំនាញរាជធានី ខេត្ត និងប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីប្រធានមន្ទីរជំនាញរាជធានី ខេត្ត
- អនុប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ មន្ត្រីបម្រើការងារក្នុងការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ

ខ. ចំពោះមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឲ្យឈប់ពីថ្នាក់ដឹកនាំក្រសួង ស្ថាប័ន។

- រាល់ច្បាប់ឈប់សម្រាកដែលបានអនុញ្ញាតរួចហើយ ត្រូវជូនព័ត៌មានដល់មន្ត្រីទទួលបន្ទុកបុគ្គលិកនៃអង្គភាព ឬ ក្រសួង ស្ថាប័នរបស់ខ្លួន។